## ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

### ១. ការបេះប្រមូលគ្រាប់ពូជ

ភាពដែលអាចរកបាននៃគ្រាប់ពូជគឺជាបញ្ហាចំបងនៅក្នុងកម្មវិធីដាំដើមឈើ។ ដើម្បីផលិតគ្រាប់ពូជដែលមានគុណភាព ជាបឋមគេត្រូវកំណត់ដើមផ្តល់ពូជ បន្ទាប់មកត្រូវធ្វើកាលវិភាគនៃការបេះប្រមូលគ្រាប់ពូជពីដើមមេនិមួយៗ។ ដើម្បីធានានូវភាពសំបូរបែបនិងរក្សាបាននូវធនធានសេនេទិក នៅក្នុងកម្មវិធីដាំដើមឈើ ការបេះប្រមូលគ្រាប់ពូជគួរអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម:

- បេះប្រមូលឬទិញគ្រាប់ពូជ ពីប្រភពគ្រាប់ពូជដែលមាននៅក្នុងតំបន់ដែលត្រូវដាំឈើ ប្រសិនបើអាចធ្វើបាន។ ចំពោះប្រភពគ្រាប់ពូជឈើនៅក្នុងព្រៃធម្មជាតិដើមមេគួរជ្រើសរើសដោយផ្អែកលើលក្ខណៈសម្បត្តិដូចខាងលើ។ គិតមកទល់បច្ចុប្បន្ននេះ មានប្រភពគ្រាប់ពូជឈើ ចំនួនជាង ២០ ដែលបានបង្កើតនៅក្នុងព្រៃធម្មជាតិ នៅក្នុងតំបន់អេកូឡូស៊ីផ្សេងៗគ្នា និងមានប្រភេទឈើអាទិភាពជាងម្ភៃប្រភេទ ដែលអាចផ្តល់គ្រាប់ពូជសំរាប់កម្មវិធីដាំដើមឈើជារៀងរាល់ឆ្នាំ។ លើសពីនេះតំបន់ផលិតគ្រាប់ពូជឈើនៃប្រភេទប្រេងខ្យល់ និងអាកាសស្យាក៏បានបង្កើតរួចហើយនៅក្នុងស្ថានីយ៍ដាំឈើមានក ហើយគ្រាប់ពូជពីប្រភពទាំងនេះនឹងអាចបេះប្រមូលបានចាប់ពីឆ្នាំ ២០០៧ តទៅ។ ក៏ប៉ុន្តែគួរចងចាំថានៅពេលដែលគ្រាប់ពូជ ត្រូវចរាចរទៅក្នុងតំបន់ អេកូឡូស៊ីផ្សេងៗគ្នា គេត្រូវគោរពតាមគោលការណ៍ណែនាំដែលមានចែងនៅក្នុងផែនទីតំបន់អេកូឡូស៊ី នៃហ្សែនព្រៃឈើ ដែលរៀបចំឡើងដោយរដ្ឋបាលព្រៃឈើនិងគំរោងគ្រាប់ពូជឈើកម្ពុជា។

នៅក្នុងករណីដែលពុំមានប្រភពគ្រាប់ពូជឈើជំហាននានាដូចខាងក្រោមនេះអាចជួយបង្ហាញផ្លូវក្នុងការបេះប្រមូលគ្រាប់ពូជដូចខាងក្រោម:

- បេះប្រមូលគ្រាប់ពូជ (ឬដកកូនឈើ) ពីដើមផ្តល់ពូជឱ្យបានច្រើន (ប្រហែល ៥០ ដើមមេ) ហើយដើមមេនិមួយៗត្រូវមានចំងាយពីគ្នាយ៉ាងហោចណាស់១០០ម។ ក៏ប៉ុន្តែនៅពេលដែលកម្មវត្ថុនៃការដាំឈើគឺដើម្បីផលិតឈើជាជាងការអភិរក្សនោះគ្រាប់ពូជគួរបេះប្រមូលពីដើមមេចំនួន២៥ដើម។ ចំណុចដែលសំខាន់នោះគឺគេត្រូវចងចាំថាមិនត្រូវបេះប្រមូលគ្រាប់ពូជដែលអាចជាបងប្អូននឹងគ្នា។ នៅក្នុងដំណុះព្រៃរេចរិល ការគោរពតាមគោលការណ៍ចំងាយអប្បរមា ១០០ម និង ចំនួនដើមមេ ២៥ ដើម គឺជាការមួយពិបាក ដូច្នេះតំរូវការនេះអាចត្រូវលើកលែងបាន អាស្រ័យទៅតាមប្រភេទឈើនិងលក្ខខណ្ឌនៃ ទីកន្លែង។
- បេះប្រមូលគ្រាប់ពូជ ពីដើមផ្តល់ពូជនិមួយៗក្នុងបរិមាណស្មើៗគ្នា និងទុកដាក់គ្រាប់ពូជដោយឡែកៗពីគ្នា រហូតដល់ពេលសាបព្រោះ ហើយអាចច្របល់បញ្ចូលគ្នាមុនពេលដាំដុះ។

- បេះប្រមូលគ្រាប់ពូជនៅក្នុងឆ្នាំដែលមានផ្លែច្រើន ដើម្បីទទួលបានគ្រាប់ពូជដែលបានមកពីការបង្កាត់គ្នារវាងដើមមេជាច្រើន ។
- បេះប្រមូលគ្រាប់ពូជឱ្យបានច្រើនដងចំពោះប្រភេទដែលផ្តល់ផ្លែផ្កាច្រើនដងក្នុងមួយឆ្នាំ ។

បច្ចេកទេសបេះប្រមូលគ្រាប់ពូជប្រែប្រួលទៅតាមប្រភេទឈើនិមួយៗ:

- សំរាប់ប្រភេទឈើខ្លះ ដូចជាអំបូរឈើទាល ប្រភេទដូនចែម ក្រកោះ និងបេងជាដើម គ្រាប់ពូជអាចត្រូវបានប្រមូលពីក្រោមដើមមេ ។ នៅក្នុងករណីខ្លះគេអង្រន់ដើមមេ ដើម្បីឱ្យគ្រាប់ធ្លាក់ (ប្រសិនបើដើមទាបល្មម) ដូចជាដើមធ្នង់ និងច្រេសជាដើម ។ គ្រាប់ពូជដែលបេះប្រមូលតាមរបៀបនេះត្រូវពិនិត្យ និងសំអាតឱ្យបានស្អាតល្អព្រោះវាអាចជាប់មកជាមួយនូវជំងឺផ្សិត ។ ប្រសិនបើអាចធ្វើបាន គ្រាប់ពូជគួរត្រូវបានបេះប្រមូលឱ្យបានច្រើនដង ដើម្បីធានាថាមានតែគ្រាប់ពូជ ដែលទើបតែទុំថ្មីៗ និងមានអត្រារស់ខ្ពស់ទេដែលត្រូវបានបេះប្រមូល ។
- សំរាប់ប្រភេទឈើខ្លះទៀត គ្រាប់ពូជអាចត្រូវបានបេះប្រមូលពីដើមមេផ្ទាល់ (ព្រោះផ្លែ/គ្រាប់វាមិនងាយធ្លាក់មកដីទេទោះបីជាទុំហើយក៏ដោយ)ចាំបាច់ត្រូវឡើងបេះលើដើមមេតែម្តង ឧទាហរណ៍ដូចជាផ្ចិលនាងនួនជាដើម ។ នៅក្នុងករណី ជាច្រើន បច្ចេកទេសងាយៗដូចជាការប្រើជណ្តើរឡើងអាចត្រូវប្រើប្រាស់ ។ ការបេះប្រមូលគ្រាប់ពូជ ពីដើមមេផ្ទាល់ជានិច្ចកាលផ្តល់គ្រាប់ពូជដែលមានគុណភាពល្អ ។

## ២.ការប្រលេះនិងសំអាតគ្រាប់ពូជ

### ២.១ ការរក្សាអត្តសញ្ញាណគ្រាប់ពូជ

បន្ទាប់ពីបានបេះប្រមូលហើយ គ្រាប់ពូជត្រូវរក្សាទុកដាក់នៅក្នុងបាវ ឬការុងដែលមានខ្យល់ចេញចូល និងត្រូវទុកនៅក្នុងម្លប់ ។ ជានិច្ចកាល កញ្ចប់គ្រាប់ពូជត្រូវមានបិទភ្ជាប់ដោយផ្លាកសញ្ញាសំគាល់ ទាំងនៅក្នុងពេលដឹកជញ្ជូន និងនៅពេលរក្សាទុកដាក់ ។ ត្រូវប្រើផ្លាកសញ្ញាសំគាល់ចំនួនពីរ: មួយចងឬបិទភ្ជាប់នៅខាងក្រៅកញ្ចប់ គ្រាប់ពូជ និងមួយទៀតដាក់ចូលទៅក្នុងកញ្ចប់គ្រាប់ពូជជាមួយនឹងគ្រាប់ពូជតែម្តង ។ ទាំងផ្លាកសញ្ញា និង ប៊ិកសរសេរលើផ្លាកសញ្ញាត្រូវធន់ទ្រាំនឹងការទទឹក ។ ប្រសិនបើអាចធ្វើបាន គេត្រូវដឹកជញ្ជូនគ្រាប់ពូជទៅកាន់ស្ថានីយ៍បណ្តុះកូនឈើឱ្យបានឆាប់រហ័សដើម្បីប្រលេះនិងសំអាតគ្រាប់ពូជ ។ ប្រសិនបើគ្រាប់ពូជមិនអាចដឹកជញ្ជូនទៅកាន់ថ្នាលបណ្តុះកូនឈើបានភ្លាមៗទេ គេត្រូវទុកដាក់វានៅក្នុងទីកន្លែងត្រជាក់ ស្ងួត និង មានខ្យល់ចេញចូលល្អ ។ ត្រូវប្រើបាវដែលធ្វើពីអំបោះ ឬក្រចៅ ដើម្បីទុកដាក់គ្រាប់ពូជ មិនមែនស្បោងប្លាស្ទិកទេ ។ ចង់ដាក់គ្រាប់ពូជត្រូវការពារពីទឹកភ្លៀង ហើយមិនត្រូវដាក់ផ្ទាល់នឹងដីព្រៃទេ ព្រោះគ្រាប់ពូជបឺតយកសំណើមពីដី ដែលធ្វើឱ្យគុណភាពថយចុះ ។

## ២.២ ការហាលគ្រាប់ពូជ

គ្រាប់ពូជដែលមានសំណើមខ្ពស់ ងាយខូចខាតដោយសារកំដៅថ្ងៃណាស់ ដូច្នេះគេត្រូវចៀសវាងការប៉ះពាល់ដោយផ្ទាល់ទៅនឹងកំដៅថ្ងៃប្រសិនបើគ្រាប់ពូជនោះមិនទាន់ស្ងួតល្អនៅឡើយទេ។ គ្រាប់ពូជដែលទើបតែបេះប្រមូលមកភ្លាមជាតំបូងគេត្រូវហាលវានៅក្នុងម្លប់ហើយនៅពេលដែលសំណើមគ្រាប់ចុះទាបហើយ ទើបគេអាចហាលសំដឹលនៅក្រោមពន្លឺថ្ងៃពេញបាន។ ប្រភេទផ្លែឈើដែលមិនអាចទុកដាក់បានយូរ (ឧទាហរណ៍ អំបូរឈើទាល) គេមិនដែលដាក់ហាលនៅក្រោមពន្លឺថ្ងៃពេញទេ។

## ២.៣ ការប្រលេះគ្រាប់ពូជ

ប្រភេទឈើផ្លែសាច់ត្រូវ ដាកក់ត្រាំក្នុងទឹករួចហើយច្របាច់យកសាច់ចេញ។ នៅពេលដែលច្របាច់យកសាច់ចេញអស់ហើយត្រូវស្រង់គ្រាប់ពូជដាក់សំដឹលនៅលើកន្ទេលឬលើក្រដាសកាសែតចាស់ៗដែលងាយបឺតយកទឹកពីគ្រាប់ពូជចេញ។ គេត្រូវឧស្សាហ៍ត្រឡប់គ្រាប់ពូជដើម្បីឱ្យស្ងួតសព្វសាច់ល្អ។

ចំពោះប្រភេទផ្លែឈើ ដែលមានសំបកផ្លែស្ងួត (ដូចជាបេង) ឬកោណ (ស្រល់ ស្វាវ) ត្រូវដាក់ហាលផ្លែនៅក្រោមកំដៅថ្ងៃពេញ រហូតទាល់តែផ្លែប្រេះទើបគេចាប់បើកផ្លែជំរុះគ្រាប់ចេញមកក្រៅ។

ចំពោះអំបូរឈើទាលគេត្រូវកាត់ស្លាបចេញ ហើយការងារនេះអាចអនុវត្តបានដោយដៃប្រសិនបើបរិមាណគ្រាប់ពូជតិចតួច។ ប្រសិនបើបរិមាណគ្រាប់ច្រើនគេត្រូវប្រើម៉ាស៊ីនកាត់ស្លាបជាជំនួយ (មិនទាន់មានប្រើនៅ ប្រទេសកម្ពុជានៅឡើយទេ)។

## ២.៤ កាសំអាតគ្រាប់ពូជ

កាសំអាតគ្រាប់ពូជអាចអនុវត្តដោយវិធីងាយៗ ដូចជាការរែង ការបណ្តែតទឹក និងការប្រើខ្យល់បក់ជាដើម។

## ២.៥ ការទុកដាក់គ្រាប់ពូជ

ប្រភេទគ្រាប់ដែលមិនអាចទុកបានយូរ (ឈើទាល ផ្ចឹក) ត្រូវយកទៅសាបនៅក្នុងថ្នាលភ្លាម បន្ទាប់ពីការបេះប្រមូលរួចដោយមិនចាំបាច់ទុកដាក់ទេ ព្រោះគ្រាប់ប្រភេទនេះមិនអាចទុកដាក់បានលើសពីរយៈពេលពីរសប្តាហ៍ទេ។ ចំពោះគ្រាប់ពូជប្រភេទឈើខ្លះទៀត (ដូចជាបេង ក្រកោះ នាងនួន ច្រេស ជាដើម) ជា ប្រភេទដែលអាចទុកដាក់បានយូរ។ គ្រាប់ពូជនៃប្រភេទឈើសិម្ពិកូល អាចថែរក្សាទុកបានរាប់ឆ្នាំនៅក្នុងលក្ខខណ្ឌអាកាសធាតុនៅក្នុងបន្ទប់។

ប្រសិនបើគ្រាប់ពូជមិនអាចយកទៅសាបនៅក្នុងថ្នាលបានភ្លាមៗទេគេត្រូវទុកដាក់វានៅក្នុងបន្ទប់ធម្មតាដែលមានខ្យល់ចេញចូលល្អ ស្ងួត និងគ្មានពន្លឺ។ ត្រូវប្រើបាវដែលធ្វើអំពីអំបោះដើម្បីច្រកគ្រាប់ពូជ ដោយមិនត្រូវប្រើស្បោងប្លាស្ទិកទេព្រោះស្បោងប្រភេទនេះពុំមានចរន្តខ្យល់ចេញចូល។ បាវឬកញ្ចប់គ្រាប់ពូជ ត្រូវការពារ ពីការទទឹក

ភ្លៀងនិងមិនត្រូវដាក់ផ្ទាល់ដីទេ ព្រោះគ្រាប់ពូជអាចស្រូបសំណើមពីដីដែលជាហេតុធ្វើឱ្យគុណភាព គ្រាប់ពូជថយចុះ។

ត្រូវចងចាំថា រាល់កញ្ចប់គ្រាប់ពូជត្រូវមានផ្លាកសញ្ញាសំគាល់ (ជានិច្ចកាលមានចំនួនពីរៈ បិទភ្ជាប់នៅខាងក្រៅ និងដាក់នៅខាងក្នុងថង់ជាមួយនឹងគ្រាប់ពូជ) ដែលបង្ហាញពីកាលបរិច្ឆេទនៃការបេះប្រមូល ឬ ទិញ។

បច្ចេកទេសក្នុងការសំអាតគ្រាប់ពូជ ការថែរក្សាទុកដាក់ និង ការសាកពិសោធន៍គ្រាប់ពូជប្រែប្រួលខុសគ្នារវាងប្រភេទឈើនិមួយៗ។ សំរាប់ប្រភេទឈើមួយចំនួន ពត៌មានទាំងនេះត្រូវបានចងក្រងនៅក្នុងសេរីនៃខិតប័ណ្ណប្រភេទឈើដែលបោះពុម្ពដោយមជ្ឈមណ្ឌលគ្រាប់ពូជឈើនៃប្រទេសដាណឺម៉ាក្ស និង ខិតប័ណ្ណប្រភេទឈើដែលបោះពុម្ពដោយគំរោងគ្រាប់ពូជឈើកម្ពុជា ។